22140567

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A: LITERATURE – STANDARD LEVEL – PAPER 1**
**KHMER A : LITTÉRATURE – NIVEAU MOYEN – ÉPREUVE 1**
**KHMER A: LITERATURA – NIVEL MEDIO – PRUEBA 1**

Friday 9 May 2014 (morning)
Vendredi 9 mai 2014 (matin)
Viernes 9 de mayo de 2014 (mañana)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a guided literary analysis on one passage only. In your answer you must address both of the guiding questions provided.
- The maximum mark for this examination paper is *[20 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez une analyse littéraire dirigée d'un seul des passages. Les deux questions d'orientation fournies doivent être traitées dans votre réponse.
- Le nombre maximum de points pour cette épreuve d'examen est *[20 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un análisis literario guiado sobre un solo pasaje. Debe abordar las dos preguntas de orientación en su respuesta.
- La puntuación máxima para esta prueba de examen es *[20 puntos]*.


© International Baccalaureate Organization 2014

https://xtremepape.rs/

*សូមអ្នកធ្វើការវិភាគបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ**គត់។ ក្នុងចម្លើយរបស់អ្នក អ្នកត្រូវឆ្លើយតបនឹងសំណួរទាំងពីរដែលបានចោទសួរ។*

**1.**

**តេជោយ៉ត** : តាំងពីលោកគ្រូអនិច្ចកម្មទៅកិច្ចការគ្រប់ជំពូកក្នុងដែនកំពង់ស្វាយនេះ ត្រូវធ្លាក់មកលើរូបខ្ញុំទាំងអស់ ប៉ុន្តែដើម្បីប្រទេសជាតិ ដើម្បីប្រជាជន ទោះបីជាការលំបាកស្មុគ្រស្មាញយ៉ាងណា ក៏ខ្ញុំខំពុះពារជានិច្ច ។ (ច្រៀង) កើតមកមួយជាតិធាតុមួយចាន មុនពេលក្ស័យប្រាណ អឺយត្រូវតែស្មោះស្ម័គ្រ (២ដង) បំរើនគរមិនឱ្យជាតិធ្លាក់ផ្តល់ម្លប់ត្រជាក់ជូនប្រជាជន ។ (និយាយ) គ្មានអាវុធអ្វីដែលមុតជាងឆន្ទៈមោះមុតនោះទេ។ ពាក្យសំដីអប់រំប្រៀនប្រដៅ ប្រកបដោយមនសិកាស្នេហាជាតិរបស់លោកគ្រូមាសជាប់ជានិច្ចក្នុងអារម្មណ៍របស់ខ្ញុំ។ (តេជោយ៉តកំពុងគិតទៅដល់ពាក្យទូន្មានរបស់តេជោមាសជាគ្រូ ហើយនាងម៉ែក៏ចូលមកដល់)

**នាងម៉ែ** : អូ ! លោកឧកញ៉ា ជំរាបសួរចាស !

**អ្នកបម្រើ** : ជំរាបសួរលោកម្ចាស់ !

**តេជោយ៉ត** : នាងម៉ែមកមានការអីឬ ?

**នាងម៉ែ** : ខ្ញុំគ្មានការអីទេ ។ ខ្ញុំមកលេងចាស ! (នាងពោលទាំងអៀនប្រៀន)

**តេជោយ៉** : មកលេងរឺ ? នៅទីនេះពុំសក្តិសមជាកន្លែងទទួលភ្ញៀវសោះ បើអញ្ចឹងសូមអញ្ជើញអ្នកនាងទៅផ្ទះវិញ ។

**នាងម៉ែ** : ចាំមិនអីទេ ! ខ្ញុំចូលចិត្តសួនច្បារណាស់ ។ ទីកន្លែងនេះជាកន្លែងប្រសើរបំផុតចំពោះខ្ញុំ ។ ជាពិសេសសូមលោកឧកញ៉ាកុំគួរសមពេក ។ បើសិនជាមិនប្រកាន់វណ្ណៈទេ សូមលោករាប់អានខ្ញុំជាមិត្តម្នាក់ផងចុះណា !

**តេជោយ៉ត** : បើនិយាយពីប្រកាន់វណ្ណៈវិញខ្ញុំឈឺចាប់ណាស់ ។ ខ្ញុំជាជនជាតិព្នងដែលអ្នកផងតែងមើលងាយមើលថោក ។ ប៉ុន្តែបើសិនអ្នកនាងប្រាថ្នារាប់អានខ្ញុំជាមិត្តភ័ក្ត សូមអ្នកនាងប្តូរពាក្យហៅខ្ញុំផ្សេងពីនេះទៅ ។

**នាងម៉ែ** : ប្តូរពាក្យ បើអញ្ចឹងខ្ញុំហៅថាបងឧកញ៉ាមែនទេ ?

**តេជោយ៉ត** : មិនទាន់ពេញចិត្តខ្ញុំទេ !

**នាងម៉ែ** : បងយ៉ត !

**តេជោយ៉ត** : ល្អណាស់ ! ល្អណាស់ ! ខ្ញុំកំព្រើកំព្រាគ្មានបងប្អូន រឺសាច់សាលោហិតទេ ។ ដូច្នេះបើមានប្អូនស្រីម្នាក់រាប់អានខ្ញុំមិនដឹងជាសប្បាយចិត្តយ៉ាងណាទេ ។

**នាងម៉ែ** : អាំ! បងចាត់ទុកខ្ញុំជាប្អូនស្រីទៅវិញទេ ! (នាងឧទានដោយភ្ញាក់ផ្អើល)

**ស្រីបម្រើ** : ខ្ញុំដើរក្នុងសួនច្បារលោកម្ចាស់ម្តងតើបានទេ ? (ស្រីបម្រើទុកឱកាសឱ្យចៅហ្វាយនាយសាសងគ្នា)

**តេជោយ៉ត** : តាមចិត្តបងស្រីចុះណាំ! (រួចសម្លឹងទៅនាងម៉ែវិញ ដោយពោលបន្ត) អ្នកនាងម៉ែហេតុអីអ្នកនាងសម្លឹងមុខខ្ញុំមិនដាក់ភ្នែកសោះអញ្ចឹង ?

**នាងម៉ែ** : ព្រោះខ្ញុំឆ្ងល់ !

**តេជោយ៉ត** : ឆ្ងល់រឿងអី ?



https://xtremepape.rs/

**នាងម៉ៃ** : បងជាយុទ្ធជនដ៏ខ្លាំងពូកែម្នាក់ ធ្លាប់ចុះប្រយុទ្ធក្រោមដាវ លំពែងនៅសមរភូមចុះហេតុអ្វីចូលចិត្តដើរក្នុងសួនច្បារអញ្ចឹង

**តេជោយ៉ត** : បើនិយាយពីមនុស្សជាតិត្រូវនិយាយពីមនោសញ្ចេតនា ។

**នាងម៉ៃ** : បងយ៉តចេះមានមនោសញ្ចេតនាដែរ !

**តេជោយ៉ត** : ខ្ញុំជាមនុស្ស ។ ខ្ញុំមិនមែនជារូបចំលាក់ពីថ្មឯណា !

**នាងម៉ៃ** : ប៉ុន្តែបេះដូងរបស់បងជាថ្ម ។

**តេជោយ៉ត** : ហា៎! បេះដូងខ្ញុំជាថ្ម ?

**នាងម៉ៃ** : ប្រាកដជាអញ្ចឹងហើយ ! (នាងម៉ៃបន្ទរ)

**តេជោយ៉ត** : ត្រូវហើយ និយាយនេះត្រូវណាស់បេះដូងខ្ញុំជាថ្ម ។

**នាងម៉ៃ** : (ច្រៀង) ថាសមុទ្រធំ អឺយ... ថាភ្នំសែនខ្ពស់ ទុក្ខខ្ញុំធំហួសសាគរគីរី (បងគ្មានយល់ចិត្តខ្ញុំសោះ) ហ៊ានកាត់កេរ្តិ៍កាត់ខ្មាសខ្លួនជានារី បងមិនប្រណីធ្វើជាពុំយល់... ។

**តេជោយ៉ត** : (ច្រៀងបន្ត) កើតជាកូនប្រុស អឺយ ដុះចិត្តក្លាហានប្រាថ្នាចង់បាន សុភមង្គល (២ដង) ជូនដល់មាតុភូមិ អង្គរនិមលកុំទាន់រវល់គិតពីស្នេហា... ។

ទី ជីហ្គួត, *រឿងតេជោយ៉ត* (១៩៨៣)

(ក) តើអ្នកយល់យ៉ាងណាចំពោះគំនិតចម្បងរបស់អត្ថបទដកស្រង់ខាងលើ ហើយតើគំនិតចម្បងនេះត្រូវបានបង្ហាញដោយរបៀបណា ?

(ខ) ចូរធ្វើការអត្ថាធិប្បាយទៅលើការប្រើប្រាស់ចម្រៀងនិងឥទ្ធិពលរបស់វាទៅលើអ្នកអាន តាមរយៈអត្ថបទដកស្រង់ខាងលើ។



https://xtremepape.rs/

**2.**

តម្រិះវិជ្ជាទាំងប៉ុន្មាន  កូនខំសូត្ររៀនលបលាក់ទុក
រៀនច្រើនចេះច្រើនចំរើនសុខ  អបាយមុខកុំសេពគប់ ។
បើកូនចង់ល្អឱ្យគប់ប្រាជ្ញ  ទើបបានកូនអាចស្រាយបញ្ហា
កុំគប់មនុស្សពាលអវិជ្ជា  នឹងនាំអាត្មាធ្លាក់រណ្ដៅ ។
មនុស្សល្ងង់មនុស្សពាលកាចសាហាវ  អាងកាំបិតដាវធ្លុះលំពែង
នឹងហាស្រដីឥតគិតក្រែង  អួតត្រូវម្នាក់ឯងមិនចេះខុស ។
មនុស្សល្ងង់ក្អេងក្អាងក្រៅរបង  ផ្អើលអស់ញាតិផងក្រែងគ្រាន់បើ
ព្រោកប្រាជ្ញច្បាប់ព្រៃមិនប្រសើរ  ដំណើរខូចខិលខ្ជិលចង់ស្លាប់ ។
បើហានិយាយឱ្យចំណេញ  ទិញចូលលក់ចេញឱ្យចំណាប់
ចាត់ចែងការងារឱ្យស្របច្បាប់  ទំលាប់ចិត្តល្អមិនក្រយូរ ។
ទោះបីកូនស្រែកឃ្លានណាស់ណា  កុំក្បត់រដ្ឋាណាមាសស្ងួន
កុំកេងប្រវ័ញ្ចលក់ជាតិខ្លួន  សូមកូនជៀសវាងឱ្យបានផុត ។
"កូនអើយបើជាតិយើងថ្កុំថ្កើង  សាសនារុងរឿងជាសុខី"
"បើជាតិលិចលង់ចុះអវចីយ៍  សាសនាគ្មានដីសង់វិហារ" ។
កូនក្រលេកមើលជាតិជិតខាង  កំពុងសំអាងរីកទឹកដី
គោរពច្បាប់រដ្ឋឥតសំចៃ  ទោះបីមានក្រឥតប្រកែក ។
គេស្រឡាញ់ជាតិលើសជីវិត  ផ្ទាល់ខ្លួនមិនគិតពេកប្រមាណ
គេហូបគ្រាន់រស់ចិញ្ចឹមប្រាណ  ទើបបានជាតិគេរីកចំរើន ។

សូរ អឿ, *បណ្ដាំឪពុក* (១៩៩៧)

(ក) តើអ្នកយល់យ៉ាងណាចំពោះសារដែលអ្នកនិពន្ធអត្ថបទកំណាព្យដកស្រង់នេះចង់ផ្ញើដល់អ្នកអាន ហើយតើសារនេះត្រូវបានបង្ហាញដោយរបៀបណា ?

(ខ) ចូរធ្វើការពិចារណាទៅលើលក្ខណៈពិសេសផ្នែករចនាបថ *(stylistic features)* នៅក្នុងអត្ថបទកំណាព្យដកស្រង់នេះជាពិសេស សូមផ្ដោតការពិចារណាទៅលើការប្រើភាសា និងរចនាសម្ព័ន្ធ។ តើលក្ខណៈពិសេសផ្នែករចនាបថទាំងនេះចូលរួមចំណែកក្នុងការបង្កើតអត្ថន័យកំណាព្យទាំងមូលយ៉ាងដូចម្ដេចខ្លះ ?



https://xtremepape.rs/